**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ : ០៣៥/២២ ក.ប/ស.ណ.ន.ប.ស.ស

# សេចក្តីណែនាំ
## ស្តីពី
## យុទ្ធនាការផ្សព្វផ្សាយរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដល់ នាយក ឬម្ចាស់រោងចក្រ សហគ្រាស គ្រឹះស្ថាន ទាំងអស់ជ្រាបថា ដោយយោងតាមប្រកាសអន្តរក្រសួងលេខ១៦៥/២២ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងប្រកាសលេខ១៧០/២២ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២២ ស្តីពីកាលបរិច្ឆេទនៃការចាប់ផ្តើមបង់ភាគទាននៃរបបសន្តិសុខសង្គម ផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ច និងរបបភាគទានដោយស្ម័គ្រចិត្ត ក្រសួងគ្រោងនឹងរៀបចំយុទ្ធនាការផ្សព្វផ្សាយរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ រយៈពេល៩០ថ្ងៃ គឺចាប់ពីខែកក្កដា ដល់ដំណាច់ខែកញ្ញា ឆ្នាំ២០២២ នេះតទៅ នៅតាមបណ្តាតំបន់សេដ្ឋកិច្ចពិសេស សួនឧស្សាហកម្ម រោងចក្រ សហគ្រាស គ្រឹះស្ថាន ទូទាំងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ក្នុងន័យនេះ ដើម្បីឱ្យការរៀបចំយុទ្ធនាការផ្សព្វផ្សាយខាងលើបានទូលំទូលាយ និងប្រកបដោយប្រសិទ្ធភាព ក្រសួងស្នើសុំដល់ នាយក ឬម្ចាស់រោងចក្រ សហគ្រាស គ្រឹះស្ថាន ត្រូវផ្តល់កិច្ចសហការផ្តល់ទីកន្លែង និងរៀបចំកម្មករនិយោជិតឱ្យបានចូលរួមស្វែងយល់ពីកាតព្វកិច្ច និងអត្ថប្រយោជន៍នៃរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលមានរយៈពេលយ៉ាងតិចចំនួន២ម៉ោងក្នុងមួយពេល។ មួយវិញទៀត នាយក ឬម្ចាស់រោងចក្រ សហគ្រាស គ្រឹះស្ថាន ត្រូវធានាថាកម្មករនិយោជិតរបស់ខ្លួនបានចូលរួមដើម្បីយល់ដឹងពីកាតព្វកិច្ច សិទ្ធិ និងអត្ថប្រយោជន៍នៃការចូលរួមក្នុងផ្នែកប្រាក់សោធន។

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រីជានាយក ឬម្ចាស់តំបន់សេដ្ឋកិច្ចពិសេស សួនឧស្សាហកម្ម រោងចក្រ សហគ្រាស គ្រឹះស្ថាន ទាំងអស់ ផ្តល់កិច្ចសហការក្នុងការអនុវត្តតាមសេចក្តីណែនាំនេះ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ១៣កើត ខែ អាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០២២

រដ្ឋមន្ត្រី

**អ៊ិត សំហេង**